00158781

Declassified to Public
06 September 2012

A 58 A 59

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

## អនុស្សរណៈផ្ទៃក្នុង

ថ្ងៃទី ២១ ខែ មករា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**ជូនចំពោះ៖** លោក Rupert SKILBECK
ប្រធានផ្នែកគាំពារការការពារក្តី

**យោង ៖** លិខិតចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨
លិខិតចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨

**ពី ៖** លោក **យូ ប៊ុនឡេង**
លោក Marcel LEMONDE
សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ ៖** ការស្នើសុំបន្តការទទួលស្គាល់មេធាវីរបស់ជនត្រូវចោទ និង ការអនុញ្ញាត្តិអោយ Case Manager និង Legal Consultant ចូលជួបជនត្រូវចោទ និង ពិនិត្យសំណុំរឿង

តាមរយៈលិខិតចុះថ្ងៃទី ០៨ និង លិខិតចុះថ្ងៃទី០៩ ខែ មករា ឆ្នាំ ២០០៨ អង្គភាពគាំពារការការពារក្តី បានស្នើសុំអោយបន្តការទទួលស្គាល់មេធាវីរបស់ជនត្រូវចោទ និង ស្នើសុំអោយអ្នកទទួលខុសត្រូវសំណុំរឿង (Case Manager) និង អ្នកពិគ្រោះយោបល់ផ្នែកច្បាប់ (Legal Consultant) ទទួលបាននូវការអនុញ្ញាត្តិទូទៅមួយក្នុងការជួបជនត្រូវចោទ និង ពិនិត្យសំណុំរឿង ។

យើងសូមជម្រាបជូនលោកប្រធានអង្គភាពថា យើងបានចេញសេចក្តីសម្រេចបន្តទទួលស្គាល់មេធាវីរបស់ជនត្រូវចោទតាមសំណើរួចរាល់ហើយ។ ប៉ុន្តែ ទាក់ទងទៅនឹងការផ្តល់ការអនុញ្ញាត្តិជាទូទៅក្នុងការជួបជនត្រូវចោទ និង ការពិនិត្យសំណុំរឿង យើងចាត់ទុកថា នេះជាសំណើដែលពាក់ព័ន្ធដល់សិទ្ធិ និង កាតព្វកិច្ចដែលភ្ជាប់ទៅនឹងសំណុំរឿងដែលគួរតែធ្វើឡើងដោយភាគីនៃសំណុំរឿងផ្ទាល់ ជាពិសេស មេធាវីរបស់ជនត្រូវចោទបន្ទាប់ពីទទួលបាននូវការទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត លើកលែងតែ លោកប្រធានត្រូវបានស្នើសុំជាក់លាក់ដោយមេធាវីរបស់ជនត្រូវចោទអោយបំពេញកិច្ចការនេះ។